ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែ មិថុនា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ | ១ |
| ២- | កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ | ២ |
| ៣- | កិច្ចប្រជុំអន្តរក្រសួងចង្អៀតលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង | ៣ |
| ៤- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១ | ៤ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្តីព្រាងរបាយការណ៍ស្តីពី

# ការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ

កាលពីថ្ងៃទី២៤ ខែឧសភា និងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំសេចក្តីព្រាងរបាយការណ៍ចំនួនពីរ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ អនុលោមតាមស្ថាប័នដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់លើអនុសញ្ញាស្តីពីសិទ្ធិកុមារថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ សេចក្តីព្រាងរបាយការណ៍ទាំងនេះ ជារបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃសញ្ញាសិទ្ធិកុមារ៖

**-របាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ**

**-របាយការណ៍ជាតិស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។**



សេចក្តីព្រាងនីមួយៗជារបាយការណ៍លើកទី១ និងលើកទី២ សរសេររួមគ្នាសម្រាប់ឆ្នាំ២០០២ ដល់ឆ្នាំ២០១០ ផ្អែកតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៦ និងឆ្នាំ២០០៧។

សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ បានឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសចប់សព្វគ្រប់ហើយកាលពីខែឧសភា ឆ្នាំ២០១០។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ** ហើយបានសម្រេចកែសម្រួលខ្លឹមសារ និងតួលេខឲ្យសមស្របតាមពេលបច្ចុប្បន្ន ពាក្យពេចន៍ ឃ្លាប្រយោគ សេចក្តីព្រាងនេះកាន់តែល្អ និងស្នើឲ្យស្ថាប័នសាមីផ្ទៀងផ្ទាត់ចំណុចក្នុងកថាខណ្ឌចុងក្រោយដែលនិយាយអំពីកាលបរិច្ឆេទនិងទីកន្លែងធ្វើសច្ចាប័ន រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន ព្រះរាជាណាចក្រថៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋកូរ៉េ ឱ្យបានច្បាស់លាស់។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕

## កិច្ចប្រជុំជំនាញបច្ចេកទេសសារឡើងវិញ លើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# មគ្គុទ្ទេសក៍ទេសចរណ៍

កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងទេសចរណ៍ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



សូមរំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃ២២ ខែកុម្ភៈ ឆ្នាំ២០១១។ អង្គប្រជុំនាពេលនោះ បានសម្រេចបង្កើតក្រុមការងារចង្អៀត ដើម្បីរៀបចំសេចក្តីព្រាងនេះឡើងវិញ។

បន្ទាប់ពីក្រុមការងារចង្អៀតបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរ ណ៍ឡើងវិញចប់សព្វគ្រប់ សេចក្តីព្រាងនេះត្រូវបានដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យពិភាក្សាឡើងវិញ។ ក្រោយពីការផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីឲ្យសេចក្តីព្រាងនេះ មានលក្ខណៈ គ្រប់គ្រាន់ ដែលឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕

## កិច្ចប្រជុំអន្តរក្រសួងចង្អៀតលើសេចក្តីព្រាងច្បាប់ស្តីពី

# ការគ្រប់គ្រងអាស៊ីដខ្លាំង

កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំអន្តរក្រសួងចង្អៀតមួយ ក្រោមអធិបតីភាព ឯកឧត្តម **កែវ ទិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ តំណាង ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ និងមន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី។



ដោយកិច្ចប្រជុំអន្តរក្រសួងកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ពុំចុះសម្រុងគ្នានៅជំពូកទី១ បទប្បញ្ញត្តិទូទៅ ត្រង់មាត្រា៤ ជាពិសេសតារាងឧបសម្ព័ន្ធអាស៊ីដខ្លាំង ដែលសមាជិកអង្គប្រជុំខ្លះពុំចង់ឲ្យមានតារាងនេះទេ ព្រោះជួបការលំបាកពេលដែលមានអាស៊ីដខ្លាំងប្រភេទផ្សេងទៀតកើតមានឡើង។ សមាជិកផ្សេងទៀតយល់ថា បើកាលណារកឃើញអាស៊ីដថ្មីអាចកំណត់ដោយអនុក្រឹត្យ ឬប្រកាសអន្តរក្រសួង។ ក៏ប៉ុន្តែប្រកាស ឬអនុក្រឹត្យពុំមានអនុភាពគ្រប់គ្រងក្នុងការផ្តន្ទាទោសដាក់ពន្ធនាគារដល់ជនល្មើសនោះឡើយ។



ដោយការពិភាក្សាលើបញ្ហាតារាងឧបសម្ព័ន្ធនេះបានអូសបន្លាយពេលស្ទើរតែពេញមួយព្រឹកពុំមានការឯកភាពគ្នានោះ ទើបឯកឧត្តម **ណា ឌីនាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល ជាប្រធានអង្គប្រជុំបានស្នើឲ្យ ឯកឧត្តម **កែវ ទិចិត្រ** សមាជិក ECOSOCC និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ជួយដឹកនាំកិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីសម្របសម្រួលលើសេចក្តីព្រាងច្បាប់នេះទាំងមូលជាពិសេសជំពូកទី១ បទប្បញ្ញត្តិទូទៅ និងជំពូកទី៤ ទោសប្បញ្ញត្តិ។

អង្គប្រជុំបានពិភាក្សាគ្នាមួយជំពូកម្តងៗ ព្រមទាំងបានធ្វើការកែសម្រួលខ្លឹមសារនៃមាត្រា៤ មាត្រា១៥ មាត្រា១៦ មាត្រា១៧ និងមាត្រា១៨។

អង្គប្រជុំនេះបានចប់ជាស្ថាពរនៅវេលាម៉ោង១១និង ៣៥នាទី នាថ្ងៃដដែល៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១*



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) លើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែឧសភា ឆ្នាំ២០១១** នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភានេះសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ១,៤% ធៀបនឹងខែមុននិងកើនឡើង ៦,៥% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ មូលហេតុចំបងនៃកំណើនសន្ទស្សន៍ថ្លៃ **ឧសភា/មេសា** គឺការឡើងថ្លៃនៃក្រុមម្ហូបអាហារដែលរួមចំណែកដល់ទៅ ៨៧% លើសន្ទស្សន៍ថ្លៃសរុប (ខែមុនអត្រារួមចំណែកនៃក្រុមនេះមានត្រឹមតែ ៥០% ប៉ុណ្ណោះ) និងការឡើងថ្លៃនៃក្រុមភោជនីយដ្ឋាន ដែលក្នុងខែនេះរួមចំណែក ៤%។

➡ គួរកត់សម្គាល់ថា ក្រុមដឹកជញ្ជូនមានការថយចុះសន្ទស្សន៍ថ្លៃ **ឧសភា/មេសា** ចំនួន ០,៥% ដែលក្នុងនោះ ថ្លៃសាំងថយចុះ១,៤% និងថ្លៃម៉ាស៊ូត ថយចុះ ១,៧%។ យ៉ាងណាមិញមុខទំនិញទាំងពីរមានការឡើងថ្លៃខ្ពស់បើធៀបនឹងខែឧសភាដូចគ្នា ឆ្នាំ២០១០ គឺ ១៦% និង ២៥% រៀងគ្នា។

➡ ក្រុមទំនិញគួរឲ្យចាប់អារម្មណ៍ បើប្រៀបធៀបខែ(ឧសភា/មេសា)មានបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ | ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ |
|---|---|---|---|---|---|
| ម្ហូបអាហារ | +២,៩% | +៨,៥% | ភោជនីយដ្ឋាន | +១% | +៨,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ | ថេរ | +៤,២% | ទំនិញ និងសេវាកម្មផ្សេងទៀត | +០,៨% | +៩,២% |
| ការដឹកជញ្ជូន | −០,៥% | +៦,៨% | | | |

* ការវិភាគជាលាយលក្ខអក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ពត៌មាន និងតួលេខពណ៌ **បៃតង** សំដៅលទ្ធផលល្អប្រសើរ និងពណ៌ **ក្រហម** សំដៅលទ្ធផលសម្រាប់ការប្រឹងប្រែង
* ដើម្បីមានសង្គតិភាពជាមួយក្រមភាសាខ្មែរ សញ្ញាក្បៀសនៅក្នុងសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ដែលជា Excel) ដោយសារបញ្ហាបច្ចេកទេស សញ្ញាក្បៀសតាងឲ្យកំណាត់ខ្ទង់ពាន់ ឯសញ្ញាចុចតាងឲ្យទសភាគវិញ។

➡ សាច់ជាមុខទំនិញលេចធ្លោដែលជះឥទ្ធិពល លើក្រុមម្ហូបអាហារ និងទំនិញប្រើប្រាស់គ្រប់មុខ។ អ្វីដែលគួរកត់សម្គាល់បំផុតគឺ សាច់ជ្រូកមួយមុខជះឥទ្ធិពល ៤៥,៣% លើកំណើនសន្ទស្សន៍ថ្លៃសរុប និងសាច់គោ ជះឥទ្ធិពល ៧,២% សាច់មាន់ ៣% និងត្រីស្រស់ ២៧%។ ដូច្នេះ សាច់បួនមុខនេះ រួមចំណែក ៨២,៥% ទៅលើការឡើងថ្លៃទំនិញប្រើប្រាស់គ្រប់មុខ។

**តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩–២០១១**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា[P] | កក្កដា[P] | សីហា[P] | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,៥% | ៩,៧% | ៩,៤% | | | | | ៦,៧% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៩% | ២,៥% | ០,៦% | | | | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | 0% | ០,៣% | ០,៦% | -០,៣% | ០,២% | 0% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | - | -៥,៧% | -៤,៨% | - | - | - | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

P: តួលេខខែមិថុនា កក្កដា និងសីហា២០១១និងប្រចាំឆ្នាំ២០១១ ជាតួលេខព្យាករណ៍( តាមវិធីសាស្ត្រ **DECOMPOSITION** )

**ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១០ និង ២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)**




ក្រាហ្វ ១ បន្តបង្ហាញនិន្នាការផ្ទុយគ្នានៃបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ក្នុងឆ្នាំ២០១០ និង ឆ្នាំ២០១១ ។ យោងតាមការព្យាករណ៍ កំណើនសន្ទស្សន៍ថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន នឹងកើនដល់ ៧,៥% ។

➡ **អត្រាប្តូរប្រាក់ :**

| ប្រភេទ | អត្រា | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ | ប្រភេទ | អត្រា | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៤ ០៨០៛/១ដុល្លារ | +១,៥% | –៣,២% | បាត/ដុល្លារ | ៣០,៣បាត/១ដុល្លារ | ១,៤% | –៦,៨% |
| ៛/បាត | ១៣៥៛/១បាត | +០,៧% | +៤,៧% | ដុង/ដុល្លារ | ២០ ៥១០ដុង/ដុល្លារ | ០% | +៧,៩% |
| ៛/ដុង | ០,១៩៨៛/១ដុង | +១% | –១០,៨% | | | | |

## ២ ) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ**នាខែឧសភាឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳ ***ចំណាយអនុវត្តបានចំនួន ៥៤៩,៨ ពាន់លានរៀល*** *(មធ្យមប្រចាំខែ៩៤% នៃគម្រោង)* ***ក្នុងនោះ ចំណាយមូលធន ៧៥,៣ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ១៤៧% នៃគម្រោង)* និង**ចំណាយចរន្ត ៤៧៤,៥ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩១% នៃគម្រោង)។

↳ បើធៀបនឹងខែមុន**ចំណាយថវិកាជាតិ** ថយចុះ ១៦% ប៉ុន្តែកើនឡើង ៩% ក្នុងរយៈពេល ១២ខែ។ ការថយចុះនៃចំណាយក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណាយចរន្តថយចុះ ២០% ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំមុនចំណាយចរន្តកើនឡើង ២% ។

**ក្រាហ្វ ២. ចំណាយថវិកាជាតិ ២០១០–២០១១**




↳ ចំណែកឯចំណាយមូលធនកើនឡើង ២២% បើធៀបនឹងខែមុន និងកើនឡើង ៩៩% ក្នុងរយៈពេល ១២ខែ។

➪ ក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធថយចុះ ២៦% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២% ក្នុងរយៈពេល ១២ខែ។ ការថយចុះនៃចំណូលសារពើពន្ធក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណូលពន្ធដារថយចុះ ៤៤% ដែលក្នុងនោះគួរឲ្យកត់សម្គាល់លើការថយចុះនៃខ្ទង់ចំណូលមួយចំនួនដូចជាពន្ធលើប្រាក់ចំណេញ អាករពិសេស ចំណូលពីកាស៊ីណូ និងចំណូលពីអាជ្ញាបណ្ណក្នុងស្រុក។ ខ្ទង់ចំណូលពន្ធដារដែលមាននិន្នាការកើនឡើងក្នុងខែឧសភានេះគឺ ពន្ធលើប្រាក់បៀវត្ស និងពន្ធលើឈ្នួលផ្ទះ-ដី។

| ក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | | ក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ✓ ពន្ធ និងអាករគយ: +១,២% | ( +៧,៨%) | ✓ នេសាទ:+៦៩% | (–៣១%) |
| ✓ ចំណូលពន្ធដារ: -៤៤% | (-៩%) | ✓ រុក្ខាប្រមាញ់:+១០៦% | (+២០២៣២%) |
| ✓ ចំណូលសារពើពន្ធផ្សេងៗ: +៣% | ( –១១%) | ✓សម្បទានរ៉ែ:-៣,៨% | (-៨២%) |
| | | ✓ អាកាសចរណ៍ស៊ីវិល:+៥៣១% | (+២៣,៨%) |
| | | ✓ ផលទុនទេសចរណ៍:-៨៣% | (-៧១%) |
| | | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍:-៣៦% | (-៤៤%) |
| | | ✓អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ):-៤២% | (+១៩%) |
| | | ✓ ចំណូលផ្សេងទៀតពុំមែនសារពើពន្ធ:+២២៧% | (+៣៤៣%) |

✓ចំណូលមិនមែនសារពើពន្ធកើនឡើង ២៥% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ២% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលមិនមែនសារពើពន្ធក្នុងខែនេះ ជាចំបងបណ្តាលមកពីកំណើនចំណូលពីអាកាសចរស៊ីវិលចំនួន ៥៣១% និងចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធចំនួន ២២៧%។

➪ ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៤៥៨,៣ ពាន់លានរៀល(*មធ្យមប្រចាំខែ ៥១% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៣៥៣,២ ពាន់លានរៀល(*មធ្យមប្រចាំខែ៧៧% នៃគម្រោង*) និង**ចំណាយមូលធន**មានចំនួន ១០៥,២ ពាន់លានរៀល(*មធ្យមប្រចាំខែ ១៩% នៃគម្រោង*) ។

➪ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ**កើនឡើង ១០% ប៉ុន្តែថយចុះ ១៣% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណាយថវិកាជាតិក្នុងខែនេះគឺបណ្តាលមកពីចំណាយចរន្តកើនឡើង ៥% ប៉ុន្តែថយចុះ ២៣% ក្នុងរយៈពេល ១២ខែ និងចំណាយមូលធន*កើនឡើង ៣៥%* និង *កើនឡើង ៥៣%* ក្នុងរយៈពេល ១២ខែ។

➪ ***តុល្យភាពថវិកាជាតិនៃខែឧសភាមានអតិរេក ៩១,៤ ពាន់លានរៀល***ដែលជាអតិរេក៥ខែជាប់គ្នា ក្នុងឆ្នាំ២០១១។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុខែឧសភាមានលក្ខណៈដូចខាងក្រោម៖

➪ **រូបិយវត្ថុទូទៅ**$M_2$មានចំនួន ***២១ ៥៥៤ ពាន់លានរៀល***កើនឡើង ២,៣% ធៀបនឹងខែមុន និងកើនឡើង ១៩,៦% ក្នុងរយៈពេល ១២ខែ។កំណើន $M_2$ ធៀបនឹងខែមុនបណ្តាលមកពីប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង ៣,១% (រយៈពេល ១២ខែ : +២០,៦%) និងប្រាក់បញ្ញើមានកាលកំណត់ និងសន្សំកើនឡើង ៦,៦% (រយៈពេល ១២ខែ:+១៧,៥%)។

➪ យោងតាមតួលេខសមាសធាតុរូបិយវត្ថុក្នុងខែឧសភានេះ ប្រាក់រៀលក្នុងសេដ្ឋកិច្ចមានចំនួន ១៨.៥% នៃរូបិយវត្ថុទូទៅ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨១.៥%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុឧសភា ២០១១



| ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល ១២ខែ | | |
|---|---|---|
| **$M_2$**<br>+២,៣% (+១៩,៦%)<br>= $M_1$ + Quasi-money | **$M_1$**<br>−១,៨%(+១៤,៨%) | រូបិយវត្ថុក្រៅធនាគារៈ−២,៩%(+១៤,៦%)<br>ប្រាក់បញ្ញើចរន្តៈ+២៧,0% (+១៩,៤%) |
| | រូបិយវត្ថុផ្សេងៗ(Quasi-money) + ៣,២% (+២0,៥%) | ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំៈ+៦,៦% (+១៧,៥%)<br>ប្រាក់បញ្ញើជារូបិយបណ្ណៈ+៣,១% (+២0,៦%) |

- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២ ៨២៧ លានដុល្លារ** ស្ថិតនៅថេរបើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៧,៩%ក្នុងរយៈពេល ១២ខែ។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** មានចំនួន **៧ ៦៧៣ ពាន់លានរៀល**កើនឡើង ៥,២% បើធៀបនឹងខែមុន និងកើនឡើង ៨,២% ក្នុងរយៈពេល ១២ខែ។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ***ក្នុងខែឧសភានេះមានចំនួន ១៣ ៨៥៧ ពាន់លានរៀលថយចុះ១,៧%បើធៀបនឹងខែមុនប៉ុន្តែកើនឡើង ២0,៧% ក្នុងរយៈពេល ១២ខែ។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ***ៈពីរខែចុងក្រោយមិនទាន់មានតួលេខ។
- ***អត្រាការប្រាក់ប្រចាំឆ្នាំ***៖

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥៣% | 0% | −0,៩% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ២២,៥៣% | +0,៣% | −១,៤% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៥% | 0% | −៧,៤% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៧,0% | +៤,៧% | +៥,៤% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែឧសភា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- កសិកម្ម៖
  - ✓ផលិតកម្មនេសាទមាន **៥១ ពាន់តោន** កើនឡើង ៤៦%បើធៀបនឹងខែមុន ប៉ុន្តែថយចុះ៩%ក្នុងរយៈពេល ១២ខែ។
- ឧស្សាហកម្ម៖
  - ✓ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២២៩ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១១% បើធៀបនឹងខែមុន និងកើនឡើង ១១,៥% ក្នុងរយៈពេល ១២ខែ។
  - ✓អគ្គិសនីផ្គត់ផ្គង់ដោយវ៉ារីអគ្គិសនីមានចំនួន ១,៥ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១00% បើធៀបនឹងខែមុន និងកើនឡើង ១៤១% ក្នុងរយៈពេល ១២ខែ។
  - ✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៨២លានដុល្លារ កើនឡើង៩% បើធៀបនឹងខែមុន និងកើនឡើង ១១% ក្នុងរយៈពេល ១២ខែ។
  - ✓ការចុះបញ្ជី ការបើកថ្មី និងការបន្តរោងចក្រ សហគ្រាស៖

| *ប្រភេទ* | *ចំនួន — ឧសភា២០១១* | *ចំនួន—មេសា២០១១* | *ចំនួន—ឧសភា២០១០* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៣ | ៩ | ១០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៦ | ១៣ | ១១ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០ | ១២ | ៩ |

## ➡ សំណង់៖

➢ **សំណង់អនុញ្ញាតឲ្យសាងសង់** ក្នុងខែឧសភា មានចំនួន ៦៨,០ ពាន់ម² ថយចុះ ៨៧% បើធៀបនឹងខែមុន និងថយចុះ ៧៨% ក្នុងរយៈពេល ១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ២៣,៦ លានដុល្លារ ថយចុះ ៨៥% បើធៀបនឹងខែមុន និងថយចុះ ៧៣% ក្នុងរយៈពេល ១២ខែ។

➢ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះ គឺលំនៅឋាន(៧០%នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| ប្រភេទ | ផ្ទៃក្រលា ពាន់ម² —ឧសភា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៧,៩ | –៦២% | –៧៥% |
| ▪ ពាណិជ្ជកម្ម | ៦,៣ | –៦២% | –៣៨% |
| ... | ... | ... | ... |
| ▪ សំណង់អនុញ្ញាតសរុប | ៦៨,០ | –៨៧% | –៧៨% |

## ➡ ការងារ៖

| ប្រភេទ | ចំនួន—ឧសភា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១ ៩៧០ | –៤៩% | –៦២% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២ ៥៧៥ | –៣៤% | +២១% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១ ១៣៨ | –២៤% | +១៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៤៣៧ | –៤០% | +២៨% |

## ➡ វិនិយោគ៖

➢ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) ក្នុងខែឧសភាមានចំនួន ៨។ គម្រោងទាំងនេះស្ថិតតែក្នុងវិស័យឧស្សាហកម្មប៉ុណ្ណោះដែលគិតជាទុនវិនិយោគស្មើនឹង **២៨,៧ លានដុល្លារ** បើធៀបនឹងខែមុនថយចុះ ១១% និងថយចុះ ៤៣% ក្នុងរយៈពេល ១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **៧ ពាន់នាក់**។

## ➡ សេវាកម្ម និងទេសចរណ៍៖

➢ ការចុះបញ្ជី និងលុបចេញពីបញ្ជី

| ប្រភេទ | ចំនួន—ឧសភា២០១១ | ចំនួន—មេសា២០១១ | ចំនួន—ឧសភា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៦៩ | ២០៣ | ១៤៣ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ៤ | ៦ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣២៦ | ២៨០ | ២១៥ |

➢ **ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ)មានចំនួន ៣៤៦,៣ ពាន់តោន ថយចុះ ១៣,៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ | | | |
|---|---|---|---|
| ▪ ផែភ្នំពេញ: –១៣% | (–១%) | ▪ ផែឧកញ៉ាម៉ុង: -៣៦,៤% | (+២៤%) |
| ▪ ផែកំពង់សោម: –១៦,៤% | (+២០%) | ▪ ផែស្រែអំបិល និងកោះកុង: –២% | (+៣៤%) |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល ១២ខែ |
|---|---|---|---|
| ▪ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤,២ | –៣២% | +៤៤% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៥៥,៦ | –១៣% | +១២% |
| ▪ ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស | ៥៣ | +១% | +២៦% |
| ▪ ចំនួនអ្នកទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ១៩០ | –១៥% | +១២% |
| ✓ តាមផ្លូវអាកាស | ៩០ | –១៥% | +៨% |
| ✓ តាមផ្លូវគោក និងទឹក | ១០០ | –១៤% | +១៥% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែឧសភា មានចំនួន ២ ១៣៤ ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៤% ប៉ុន្តែកើនឡើង ១៩% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ១២ខែ | ទំនិញ | %Δធៀបនឹងខែមុន | %Δ១២ខែ |
|---|---|---|---|---|---|
| ប្រេងខ្មៅ | +១៦៣% | +១១% | ប្រេងសាំង | 0% | +១៨% |
| ដែកសំណង់ | +៦% | –១៧% | ប្រេងម៉ាស៊ូត | –៥% | –៥% |
| ស៊ីម៉ង់ត៍ | +២៩% | +៩% | ឧស្ម័ន | –១៩% | –១៥% |
| គ្រឿងអេឡិចត្រូនិក | +១១% | –១៦% | រថយន្តសរុប (គ្រឿង) | –៦% | +១% |
| ត្រាក់ទ័រនិងគោយន្ត | +២២% | +២៦% | រថយន្តសរុប (ព.ល.រ) | +២% | +៩% |
| ជីនិងថ្នាំកសិកម្ម | +៦៦% | +១៧0% | ម៉ូតូ | 0% | –៣៣% |
| ភេសជ្ជៈ | +៧% | +១៣៦% | ស្រូវសាលី | –៤១% | +៣២% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +២% | +៤% | អង្ករ | –៣៧% | –៤៧% |
| | | | ផ្លែឈើនិងបន្លែ | –៨% | –៦៤% |

➡ **ការនាំចេញ** ក្នុងខែឧសភា ឆ្នាំ២០១១ មានចំនួន ១ ៤២២ ពាន់លានរៀល (៦៧% នៃការនាំចូល)កើនឡើង ៥,៥% ធៀបនឹងខែមុន និង កើនឡើង ២១% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | +១,៥% | +១២% | អង្ករ | +៣៨% | +៤0១% |
| កៅស៊ូ | +១២៥% | +១១៧% | ផលិតផលនេសាទ | –៥១% | –៧៨% |
| ផលិតផលឈើកែច្នៃ | +៣៦% | +២៨៦% | | | |

➡ *ក្នុងខែឧសភា ឆ្នាំ២០១១នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជា មានឱនភាពចំនួន ៧១២ ពាន់លានរៀល ស្មើនឹង ១៧៤,៥ លានដុល្លារ ស.រ.អ.។*

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | រយៈពេល ១២ខែ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | ថ្លៃសាច់ជ្រូក<br>ថ្លៃសាច់គោស្រស់<br>ថ្លៃសាច់មាន់ស្រស់<br>ថ្លៃត្រីស្រស់ | +១២%<br>+៤,៨%<br>+៣,៣%<br>+៥,២% | +១៥%<br>+៨,៧%<br>+៨,៣%<br>+១0% | សាច់ជាមុខទំនិញដែលមានការរួមចំណែកធំ (៨២,៥%) ទៅលើការឡើងថ្លៃទំនិញប្រើប្រាស់គ្រប់មុខ |
| ២. | ចំណូលពន្ធដារ | –៤៤% | –៩% | មានការថយចុះគួរឲ្យចាប់អារម្មណ៍ នៃពន្ធលើប្រាក់ចំណេញ អាករពិសេស ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក ចំណូលពីកាស៊ីណូ |
| ៣. | សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម$^{២}$) | –៨៧% | –៧៨% | ទោះជាការអនុញ្ញាតឲ្យសាងសង់ មានការថយចុះយ៉ាងគំហុកក្នុងខែនេះក៏ដោយ បើប្រៀបធៀបរយៈពេល ៥ខែដូចគ្នា ២០១១/២០១០ សូចនាករនេះ បើគិតជាក្រឡាផ្ទៃ កើនឡើង ៨៩% ក្នុងនោះភាគច្រើនជាលំនៅឋាន និងសំណង់ឧស្សាហកម្ម |
| ៤. | ការនាំចេញផលិតផលឈើកែច្នៃ | +៣៦% | +២៨៦% | ក្នុងបីខែចុងក្រោយនេះ ការនាំចេញផលិតផលឈើកែច្នៃ មានតួលេខខ្ពស់គួរឲ្យកត់សម្គាល់។ បើប្រៀបធៀប រយៈពេល ៥ខែដូចគ្នា២០១១/២០១០ការនាំចេញមុខទំនិញនេះ កើនឡើង ២៨៦,៤%។ |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១)មូលហេតុធំបំផុតនៃការឡើងថ្លៃទំនិញប្រើប្រាស់ក្នុងខែឧសភានេះ គឺវិសមភាពនៃតម្រូវការ និងការផ្គត់ផ្គង់។ ឥទ្ធិពលចំបងនៃក្រុមសាច់មកលើអតិផរណាបង្ហាញភាពមានកម្រិតនៃផលិតកម្មក្នុងស្រុកសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដែលកើនឡើងជាលំដាប់។

២)ការអនុវត្តចំណាយថវិកាជាតិក្នុងអំឡុង៥ខែដើមឆ្នាំនេះ មានការយឺតយ៉ាវធៀបនឹងគម្រោង ជាពិសេសការអនុវត្តចំណាយមូលធន។ ដូច្នេះហើយយើងសង្កេតឃើញ អតិរេកថវិកាជាតិ ក្នុង៥ខែដើមឆ្នាំនេះ។ ចំណែកខាងចំណូលថវិកាជាតិវិញ ចំណូលពន្ធដារ នៅតែមានទំហំទាបខ្លាំង ធៀបនឹង ពន្ធ និងអាករគយ : សរុប៥ខែ ដើមឆ្នាំ២០១១ ចំណូលពន្ធដារសម្រេចបាន ៣៧% នៃចំណូលសរុប ឯពន្ធ និងអាករគយ សម្រេចបាន ៦៣% នៃចំណូលសរុប។ ក្នុងឆ្នាំ២០១០ អំឡុងពេល ៥ខែដូចគ្នា សូចនាករទាំងពីរនេះ ស្មើនឹង ៣៥% និង ៦៥% រៀងគ្នា។

៣)វិស័យសំណង់ក្នុងខែនេះ មានការស្រុតចុះខ្លាំង បន្ទាប់ពីកំណើន ៤ខែជាប់គ្នា នាដើមឆ្នាំ២០១១នេះ។

៤)នៅខែក្រោយ យោងតាមការព្យាករណ៍ សន្ទស្សន៍ថ្លៃនឹងកើនឡើង 0,៩% ធៀបនឹងខែឧសភានេះ និងកើនឡើង ៧,៥% (អាចជាជាអតិផរណាប្រចាំខែមិថុនា) ក្នុងរយៈពេល ១២ខែ។

### *ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*

១) ក៏ប្រហាក់ប្រហែលនឹងអ្វីដែលបានចែងក្នុងខែមុនៗដែរ កម្ពុជាត្រូវទាញផលចំណេញឲ្យបានអតិបរិមាពីឧត្តមភាពប្រៀបធៀបនៃវិស័យកសិកម្ម ដែលមានដូចជា ដីទំនេរ កំលាំងពលកម្មច្រើនដែលមានគុណវុឌ្ឍទាបស្ថិតក្នុងវិស័យនេះស្រាប់។ល។ ការនេះអាចសម្រេចបានតាមរយៈការបង្កើតឲ្យបាននូវមូលដ្ឋានផលិតកម្មរឹងមាំ ទាំងការដាំដុះដំណាំ និងការចិញ្ចឹមសត្វ ដើម្បីប្រែក្លាយវិស័យនេះទៅជាធុរកិច្ចខ្នាតធំ ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងក្រៅប្រទេស។

- ត្រូវតម្រង់កម្មវិធីវិនិយោគលើការដាំដុះ និងការចិញ្ចឹមសត្វ សំដៅធ្វើទំនើបកម្មវិស័យនេះ
- ត្រូវបង្កើតលក្ខខណ្ឌដែលមានលក្ខណៈជាប្រព័ន្ធនៃធុរកិច្ច ដោយមានផលិតកម្មគាំទ្រដូចជា **ការផលិតជីកសិកម្ម និងចំណីសត្វ**ជាដើម និងមានហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ដូចជាការប្រមូលទិញកសិផល និងផ្លូវនាំចេញ។

២) ដោយសារការប្រើប្រាស់ធ្យូង–អុស ជាថាមពលចំអិនកាន់តែដាក់សម្ពាធលើធនធានធម្មជាតិ និងដោយសារនិន្នាការកើនឡើងជាលំដាប់នៃថ្លៃហ្គាស កម្ពុជាគួរចាប់ផ្តើមពិចារណាអំពីជំរើសការងាកទៅរកការប្រើប្រាស់អគ្គិសនី ជាថាមពលចំអិនវិញ ដោយគួរចាប់ផ្តើមពីទីក្រុងទៅ៕



# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៦/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ។<br>៤-បញ្ហាផ្សេងៗ នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ២ | ០៥/០៦/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋរស់នៅស្រុកព្រៃកប្បាស នៅឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ |
| ៣ | ០៦/០៦/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យម ឆ្នាំ២០១០ និងបើកជាផ្លូវការនៃវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី** នៅសាលាភូមិន្ទរដ្ឋបាល។ |
| ៤ | ០៦/០៦/១១<br>ម៉ោង ១៧ : ៣០ នាទី | ប្រជុំពិភាក្សាការងារជាមួយស្ថានទូតកូរ៉េខាងជើង នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៨-០៩/០៦/១១<br>ពេញមួយថ្ងៃ | ចូលរួមជាសមាជិកគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ក្នុងសម័យប្រជុំបច្ចេកទេសលើកទី២០ នៃ (CIC) ដឹកនាំដោយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅខេត្តសៀមរាប ។ |
| ៦ | ១០/០៦/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៧ | ១៣/០៦/១១<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំអង្គប្រជុំបន្ត ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ។<br>២-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៨ | ១៤/០៦/១១<br>ម៉ោង ០៩ : ៣០នាទី | ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន GENTING នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១៥/០៦/១១<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារសិក្សាថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។ |
| ១០ | ១៥/០៦/១១<br>ម៉ោង ១៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈកិច្ចព្រមព្រៀងគោល នៃការសាងសង់រោងចក្រចម្រាញ់ប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូអិលធីឌី (CPC) និងពិធីពិសារភោជនាហារ បន្ទាប់ពីពិធីចុះហត្ថលេខា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១៦/០៦/១១<br>ម៉ោង ១៤ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីថ្លែងបបកថាផ្សព្វផ្សាយ ដើម្បីសេចក្តីស្រឡាញ់ចំពោះប្រាសាទព្រះវិហារ និងការភូតកុហករបស់ថៃ ពាក់ព័ន្ធបញ្ហាប្រាសាទព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទចតុមុខ ។ |
| ១២ | ២១/០៦/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមចុះពិនិត្យការដ្ឋានសាងសង់អគារមជ្ឈមណ្ឌលតំកល់ឯកសារច្បាប់ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅរាជធានីភ្នំពេញ ។ |
| ១៣ | ២៣/០៦/១១ ម៉ោង<br>០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំការងារសាងសង់អគារទីស្នាក់ការអាជ្ញាធរអប្សរាខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ២៤/០៦/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ។<br>២-សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ។<br>៣-បញ្ហាផ្សេងៗ នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៥ | ២៤/០៦/១១<br>ម៉ោង ១៩ : ៣០នាទី | ចូលរួមក្នុងពិធីជប់លៀងជាមួយអគ្គរដ្ឋទូតបារាំង នៅស្ថានទូតបារាំង ។ |
| ១៦ | ២៧/០៦/១១<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគេន-ប្រគល់សញ្ញាបត្រ បរិញ្ញាបត្រ និងវិញ្ញាបនបត្រគរុកោសល្យ ដល់សមណនិស្សិត-និស្សិត គរុនិស្សិត នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាលសន្និសីទចតុមុខ ។ |
| ១៧ | ២៨/០៦/១១<br>ម៉ោង ០៧ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទីញអបអរសាទរខួបលើកទី៦០ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨.០៦.១៩៥១-២៨.០៦.២០១១) នៅបរិវេណខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា (ចំការមន) ។ |
| ១៨ | ២៩/០៦/១១<br>ម៉ោង ០៨ : ៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៩ | ៣០/០៦/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមជាអធិបតីក្នុងពិធីមីទ្ទីញអបអរសាទរខួបលើកទី៦០ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨.០៦. ១៩៥១-២៨.០៦.២០១១) នៅស្រុកព្រៃកប្បាស ខេត្តតាកែវ ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន សមាជិក-សមាជិកា និង អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១១

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៥/០៦/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈកិច្ចព្រមព្រៀងគោល នៃការសាងសង់រោងចក្រចម្រាញ់ប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូអិលធីឌី (CPC) និងពិធីពិសារភោជនាហារ បន្ទាប់ពីពិធីចុះហត្ថលេខា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ១៦/០៦/១១ | ចូលរួមជាកិត្តិយសក្នុងពិធីថ្លែងបឋកថាផ្សព្វផ្សាយ ដើម្បីសេចក្តីស្រឡាញ់ចំពោះប្រាសាទព្រះវិហារ និងការភូតកុហករបស់ថៃ ពាក់ព័ន្ធបញ្ហាប្រាសាទព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទចតុមុខ ។ |

## ឯកឧត្តម ឡុង ឈាង សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/០៦/១១ | ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/០៦/១១ | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ១៣/០៦/១១ | ដឹកនាំអង្គប្រជុំបន្ត ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ។<br>២-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ១៥/០៦/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈកិច្ចព្រមព្រៀងគោល នៃការសាងសង់រោងចក្រចម្រាញ់ប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូអិលធីឌី (CPC) និងពិធីពិសារភោជនាហារ បន្ទាប់ពីពិធីចុះហត្ថលេខា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ១៦/០៦/១១ | ចូលរួមជាកិត្តិយសក្នុងពិធីថ្លែងបឋកថាផ្សព្វផ្សាយ ដើម្បីសេចក្តីស្រឡាញ់ចំពោះប្រាសាទព្រះវិហារ និងការភូតកុហករបស់ថៃ ពាក់ព័ន្ធបញ្ហាប្រាសាទព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទចតុមុខ ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម គឹម សយសារមិលៀន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម ជួន ពិណ | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម ម៉ម សាទ | សមាជិកបម្រុង ក.ស.វ. |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម ហេង រតនា | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក ស៊ី វាសនា | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក បេង ប៊ុនណា | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក ភក្ដិ ... | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ៖ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ៖ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in